ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ:៥១៦/១២-៩-២០០៨

សាលដីកា

លេខ:១៦(៣)/១៧-០២-២០០៩

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី១៧-០២-២០០៩ :

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក ចៅក្រមប្រឹក្សា

លោក ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

-ដើមចោទឈ្មោះ [redacted] នន់ ភេទប្រុស អាយុ៥៩ឆ្នាំ មុខរបរគ្រូបង្រៀន ទីលំនៅភូមិថ្នល់ ឃុំគោកពោធិ ស្រុកបូរីជលសា ខេត្តតាកែវ ឪពុកឈ្មោះ សាន់(ស) ម្ដាយឈ្មោះ អ៊ុន(ស) ប្រពន្ធឈ្មោះ [redacted] ស្រេន (ចុងបណ្ដឹងឧទ្ធរណ៍) ។

-ចុងចម្លើយឈ្មោះ [redacted] ស្រេន ភេទស្រី អាយុ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់គ្រឿងសំណង់ ទីលំនៅភូមិថ្នល់ ឃុំគោកពោធិ ស្រុកបូរីជលសា ខេត្តតាកែវ ឪពុកឈ្មោះ [redacted] វ៉ា(ស) ម្ដាយឈ្មោះ សៀក(ស) ប្ដីឈ្មោះ [redacted] នន់ (ដើមបណ្ដឹងឧទ្ធរណ៍) ។

-មេធាវី [redacted] តំណាងដោយអាណត្តិ

<u>**អំពីវិវាទ**</u>: ប្ដឹងលែងលះប្រពន្ធ និង បែងចែកទ្រព្យសម្បត្តិរួម ។

## អង្គហេតុ និង ចំណុចវិវាទ

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៣-៥-២០០៧ របស់ឈ្មោះ [redacted] នន់ ប្ដឹងលែងលះប្រពន្ធ និង បែងចែកទ្រព្យសម្បត្តិរួម ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយឈ្មោះ [redacted] ស្រេន កាលពីឆ្នាំ១៩៨៨ ហើយមានកូន៤នាក់ គឺទី១ឈ្មោះ [redacted] សុខា ទី២ឈ្មោះ [redacted] ចន្ធូ ទី៣ឈ្មោះ [redacted] សុភារិទ្ធ ទី៤ឈ្មោះ [redacted]

២៩៥

សុមានិត ពេលនោះមានភ្លើងឆេះផ្ទះអស់ នៅសល់ដីមួយប្លង់(ប្លង់ផ្ទះ) មានទំហំ៧មគុណ៣០ម ក្នុងអំឡុងពេលនោះគ្រួសារខ្លួនមានរឿងវិវាទបែកគ្នាមួយរយៈ ទើបបងប្អូនញាតិមិត្តផ្សះផ្សារជាគ្រួសារឡើងវិញ នៅឆ្នាំ១៩៩៦ តែកូនក្នុងបន្ទុកឈ្មោះ [redacted] សុខា និង ឈ្មោះ [redacted] ចន្ធូ មានគ្រួសាររៀងខ្លួនហើយ ។ ចាប់ពីឆ្នាំ១៩៩៦ ដល់បច្ចុប្បន្ន ខ្លួន និងប្រពន្ធព្រមទាំងកូនពីរនាក់ រស់នៅជាមួយគ្នា ហើយទ្រព្យដែលរកបានជាមួយគ្នា គឺដីស្រែ១១.៥ហិកតា ដីប្លង់ផ្ទះមួយកន្លែងទំហំ១០មគុណ៧២ម ផ្ទះចំនួន៣ តែឈ្មោះ [redacted] ស្រែន លក់ផ្ទះមួយតម្លៃ៤០០០០០០៛ និង ឥវ៉ាន់ និង គ្រឿងទេសតម្លៃ៧០០០$ ម៉ូតូមួយគ្រឿងតម្លៃ៦៥០$ មាសពីរជី ។

១-ការអះអាងរបស់ដើមចោទឈ្មោះ [redacted] នន់ អះអាងថា: នៅពេលនេះ ខ្លួននៅតែប្តឹងសុំលែងលះដដែល។ ខ្លួនបានបែកលំនៅសង្វាសម្តង ហើយបានចូលរស់នៅជាមួយគ្នាវិញ ។ ការរស់នៅជាមួយគ្នាកន្លងមក មានទ្រព្យសម្បត្តិដូចជាផ្ទះ ដី ម៉ូតូ តែទ្រព្យនេះដូចជាដី និង ផ្ទះ បានកាត់កងបំណុល ។ ពេលខ្លួនចុះពីផ្ទះលើកទី១ បានយកម៉ូតូទៅជាមួយមួយគ្រឿងមែន ។ ដីស្រែដែលខ្លួនមានជាមួយនឹងប្រពន្ធ ទំហំ១០ហិកតា ក្រោយមកលក់អស់នៅសល់៦ហិកតា តែ៤ហិកតាដែលលក់អស់នោះ ខ្លួនអត់បានដឹងទេ ។

នៅពេលនេះខ្លួនសំណូមពរ សុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល ។

២-ការអះអាងរបស់ចុងចម្លើយឈ្មោះ [redacted] ស្រែន អះអាងថា: ខ្លួនមិនសុខចិត្តអំពីទ្រព្យសម្បត្តិរួម ដែលសាលាដំបូងបែងចែកពុំត្រឹមត្រូវ ដោយហេតុថា- ប្តីខ្លួនបានចុះចោលខ្លួន ហើយបានយកម៉ូតូទៅជាមួយ០១គ្រឿង ។ ចំណែកដីជាទ្រព្យរួមមានសល់តែ៦ហិកតា ឯផ្ទះបានកាត់បំណុលគេ ។ ដីមួយកន្លែងនៅមុខផ្សារឱ្យកូនសង់ផ្ទះ មិនមែនទ្រព្យរួមទេ ។

នៅពេលនេះខ្លួនសំណូមពរ សុំទាមទារយកទ្រព្យសម្បត្តិទាំងអស់ សុំបដិសេធសាលក្រមរបស់សាលាដំបូងចោល ។

## តំណាងមហាអយ្យការសន្និដ្ឋានៈ

រឿងនេះពុំមានពាក់ព័ន្ធជាមួយកូនជាអនិតិជនទេ សូមលោកចៅក្រមពិចារណាសម្រេចទៅតាមច្បាប់ចុះ ។

-មេធាវី [redacted] តំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ស្រែន ធ្វើសេចក្តីថ្លែងហេតុថា: កូនក្តីខ្លួនបានលើកហេតុផលបញ្ជាក់ជូនតុលាការអស់ហើយ នៅពេលនេះខ្លួនសំណូមពរ សុំបដិសេធសាលក្រមរបស់សាលាដំបូងចោល សុំឱ្យសាលាឧទ្ធរណ៍សម្រេចជាថ្មី តាមការទាមទាររបស់កូនក្តីខ្លួន ដូចបានលើកឡើងខាងលើ ។

## សំអាងហេតុ

## យល់ឃើញថាៈ

១-យល់ឃើញថា: បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-៥-២០០៨ របស់ឈ្មោះ [redacted] ស្រែន ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-យល់ឃើញថា: គូភាគីបានរួមរស់ជាអនីតិសង្វាសជាមួយគ្នាឆ្នាំ១៩៨៨ គ្មានកូននឹងគ្នាទេ មានតែកូនដើមរៀង១ខ្លួន ។ ការរួមរស់ជាមួយគ្នាដំបូង គូភាគីបានចាប់ដីសំរាប់ស្នាក់នៅមួយកន្លែង ស្ថិតនៅជាប់ផ្សារថ្មស ក្នុងឃុំគោកពោធិ ។ ក្រោយមកគូភាគីបានបែកលំនៅគ្នា ដោយដើមចោទបានយកម៉ូតូ០១គ្រឿង តម្លៃជាង០២តម្លឹងចេញពី

ផ្ទះ ហើយចុងចម្លើយបានគ្រប់គ្រងដីខាងលើ ហើយនៅឆ្នាំ១៩៩៣ ចុងចម្លើយក៏បានឱ្យដីនេះទៅកូនឈ្មោះ [redacted] សុផល ហើយឈ្មោ[redacted] សុផល ក៏បានសាងសង់ផ្ទះដើម្បីរស់នៅ ដែលមានពាក្យសុំសាងសង់ ចុះថ្ងៃទី០៧-០៣-២០០៣។ ក្រោយមកឆ្នាំ១៩៩៦ ដើមចោទ និង ចុងចម្លើយក៏បានរួមរស់ជាមួយគ្នាម្តងទៀត ដោយអនីតិសង្វាសរហូតមកដល់ថ្ងៃប្តឹងផ្តល់លែងលះ មកតុលាការ ។

៣-យល់ឃើញថា: ក្នុងអំឡុងពេលរួមរស់ជាមួយគ្នា គូភាគីមានទ្រព្យសម្បត្តិរួម គឺដីស្រែចំនួន៦ហិកតា កូនផ្ទះលក់គ្រឿងសាងសង់ ដែលសង់នៅលើទំនប់សាធារណៈ ដីលំនៅដ្ឋានទំហំ១០ម x ៦៥ម ផ្ទះមួយនៅមុខស្ថានីយបូមទឹក ស្ថិតនៅក្នុងឃុំគោកពោធិ ដែលសង់នៅលើទំនប់សាធារណៈ ដែលត្រូវបានតុលាការ បែងចែកតាមសាលក្រមរដ្ឋប្បវេណីលេខ:២១(ក) ចុះថ្ងៃទី២៩-៤-២០០៨ ប៉ុន្តែត្រូវបានចុងចម្លើយឈ្មោះ [redacted] ស្រេន មិនសុខចិត្តគ្រង់ចំណុចប្រគល់ដីទំហំ១០ម x ៦៥ម ឱ្យដើមចោទ និង យកដីសំរាប់សង់លំនៅដ្ឋាន១កន្លែងជាប់នឹងផ្សារថ្មស មកធ្វើការបែងចែកជាទ្រព្យសម្បត្តិរួម ។

៤-យល់ឃើញថា: តាមការយល់ឃើញខាងលើ ដីមួយកន្លែងសំរាប់សង់លំនៅដ្ឋាន ឋិតនៅជាប់ផ្សារថ្មស ក្នុងឃុំគោកពោធិ គឺជាទ្រព្យដើមរបស់ចុងចម្លើយ ដែលបានធ្វើការបែងចែកគ្នា ជាមួយដើមចោទរួចហើយៗត្រូវបានចុងចម្លើយប្រគល់ឱ្យកូនឈ្មោះ[redacted] សុផល កាន់កាប់គ្រប់គ្រងជាកម្មសិទ្ធិរួចហើយ ។

៥-យល់ឃើញថា: តាមការទាញហេតុផលដោយផ្ទាល់មាត់នាសាលាឧទ្ធរណ៍ ចុងចម្លើយបានបញ្ជាក់ថា នៅពេលដែលដើមចោទចុះចេញពីផ្ទះ រហូតមកដល់ពេលដាក់ពាក្យប្តឹងសុំលែងលះមកតុលាការ ដើមចោទបានយកម៉ូតូដែលជាទ្រព្យសម្បត្តិរួមចេញពីផ្ទះ ហើយទ្រព្យសម្បត្តិរួមដែលនៅសល់ ដូចមាននៅក្នុងការយល់ឃើញខាងលើ គប្បីក្រុមប្រឹក្សាសាលាឧទ្ធរណ៍ ធ្វើការបែងចែកទ្រព្យសម្បត្តិរួមឡើងវិញ ។

៦-យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខ:២១(ក) ចុះថ្ងៃទី២៩-៤-២០០៨ របស់សាលាដំបូងខេត្តតាកែវ សំរេចត្រឹមត្រូវតាមច្បាប់ហើយ លើកលែងតែចំណុចទី៤ ស្តីអំពីការបែងចែកទ្រព្យសម្បត្តិរួម ត្រូវបដិសេធចោល និង សំរេចជាថ្មី ដោយបែងចែកដូចការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## ទិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-៥-២០០៨ របស់ឈ្មោះ[redacted] ស្រេន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ:២១(ក) ចុះថ្ងៃទី២៩-៤-២០០៨ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការ លើកលែងតែចំណុចទី៤ នៃសាលក្រមត្រូវបដិសេធចោល និង សំរេចជាថ្មីដូចខាងក្រោម:

ក-ប្រគល់ដីសង់លំនៅដ្ឋានទំហំ១០ម x ៦៥ម ផ្ទះលក់គ្រឿងសាងសង់មួយ ដែលស្ថិតនៅលើទំនប់សាធារណៈ និង ដីស្រែចំនួន០៣ហិកតា ឱ្យទៅឈ្មោះ[redacted] ស្រេន កាន់កាប់គ្រប់គ្រងនៅពេលសាលដីកានេះ ចូលជាស្ថាពរ ។

ខ-ប្រគល់ផ្ទះមួយជាប់ប្រឡាយមុខស្ថានីយបូមទឹក និង ដីស្រែ០៣ហិកតា ឱ្យទៅដើមចោទឈ្មោះ [redacted] ននំ កាន់កាប់គ្រប់គ្រងនៅពេលសាលដីកានេះចូលជាស្ថាពរ ។

២៩៣



Scanned with CamScanner

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

៤-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី១៧-០២-២០០៩ ទុកសិទ្ធិឱ្យប្តឹងសាទុក្ខ រយៈពេលមួយ១ខែ គិតពីថ្ងៃ បានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|

ហត្ថលេខា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២០ ខែ ក្ត ឆ្នាំ ២០០៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

២៥៨



២១៥